មាត្រា ៤.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានី ភ្នំពេញ ថ្ងៃ ទី ២៧ ខែ សីហា ឆ្នាំ ១៩៩៧

ហត្ថលេខា និង ត្រា

នាយករដ្ឋមន្ត្រី ទី ១ នាយករដ្ឋមន្ត្រី ទី ២

**អ៊ឹង ហួត** **ហ៊ុន សែន**

***

## អនុក្រឹត្យ លេខ ៤៥ អនក្រ បក

## ស្តីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និង ផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១០៩៤ /៩៣ ចុះថ្ងៃ ទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

### សំរេច

មាត្រា ១.- ត្រូវបានរំសាយទីស្នាក់ការត្រួតពិនិត្យ ដែលបានបង្កើតកន្លងមកទាំងអស់ ស្ថិតនៅតាមច្រកព្រំដែន និង ផ្លូវគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.- ត្រូវបានបង្កើតឡើងវិញនូវទីស្នាក់ការត្រួតពិនិត្យតាមច្រកចេញ-ចូលនៅព្រំដែន និងនៅតាមផ្លូវគមនាគមន៍ ជាអាទិ៍ ផ្លូវគោក ផ្លូវទឹក ផ្លូវដែក ផ្លូវអាកាស នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់កណ្ដាល មានដូចខាង ក្រោម ។

**ក.អំពីផ្លូវជាតិ:**

១-ផ្លូវជាតិលេខ១ ពីព្រំដែនបាវិត មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : បាវិត(ខេត្តស្វាយរៀង) ។

២- ផ្លូវជាតិលេខ២ ពីព្រំដែនភ្នំដិន មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច: ភ្នំដិន (ខេត្តតាកែវ)

៣- ផ្លូវជាតិលេខ ៤ ពីក្រុងព្រះសីហនុ មកដល់រាជធានីភ្នំពេញមាន ០២ ចំណុច : កំពង់ផែក្រុងព្រះសីហនុ និងក[illegible] (ខេត្តកំពង់ស្ពឺ)

៤-ផ្លូវជាតិលេខ ៥ ពីព្រំដែនប៉ោយប៉ែត មកដល់រាជធានីភ្នំពេញមាន ០២ ចំណុច: ប៉ោយប៉ែត និងទឹកថ្លា (ខេត្តបន្ទាយមានជ័យ)

**ខ.អំពីផ្លូវទឹក:**

១- តាមដងទន្លេមេគង្គលើពីព្រំដែនប្រទេសឡាវ មកដល់រាជធានីភ្នំពេញមាន ០១ចំណុច : អូរស្វាយ-កោះឈើទាលធំ (ខេត្តស្ទឹងត្រែង) ។

២- តាមដងទន្លេមេគង្គក្រោម ពីព្រំដែនប្រទេសវៀតណាម មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច: កោះរការ-ក្អមសំណរ ។

៣- តាមដងទន្លេបាសាក់ ពីព្រំដែនប្រទេសវៀតណាម មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : ខ្ពបតាំងយូ-ជ្រៃធំ ។

៤- នៅរាជធានីភ្នំពេញមានកំពង់ផែពាណិជ្ជកម្មអន្តរជាតិទីក្រុងភ្នំពេញ ។

**គ. អំពីផ្លូវដែក :**

- ផ្លូវដែកទាំងពីរទិសមាន ០៥ ចំណុច : ស្ថានីយ៍រាជាយស្ម័យានកម្ពុជា (ភ្នំពេញ ) ស្ថានីយ៍រថភ្លើងក្រុងព្រះសីហនុ ស្ថានីយ៍រថភ្លើង ទីរួមខេត្តពោធិសាត់ ស្ថានីយ៍រថភ្លើងទីរួមខេត្តបាត់ដំបង និងស្ថានីយ៍រថភ្លើងខេត្តបន្ទាយមានជ័យ ។

**ឃ. អំពីផ្លូវសមុទ្រ :**

១- ខេត្តកោះកុងមាន ៥ចំណុច : កោះស្ដេច ប៉ាក់ខ្លង ថ្មស ចាំយាម និងស្រែអំបិល ។

២- ក្រុងព្រះសីហនុមាន ៣ចំណុច : កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ ទំនប់រលក ស្ទឹងហាវ

៣- ខេត្តកំពតមាន ៤ចំណុច : ទាន់ហាន់ កោះសេះ ត្រពាំងល្ពៅ និងផែ ទីរួមខេត្តកំពត ។

៤- ទីក្រុងកែបមាន ១ចំណុច : ផែក្រុងកែប ។

**ខ- អំពីផ្លូវអាកាស :**

-ផ្លូវអាកាសមាន ០៨ចំណុច: អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង អាកាសយានស្ថាន កងកេងក្រុងព្រះសីហនុ, ខេត្តសៀមរាប, ទីរួមខេត្តកោះកុង, វាលបែកចានទីរួមខេត្តបាត់ដំបង ទីរួមខេត្តស្ទឹងត្រែង, បានលុងទីរួមខេត្តរតនគីរី និងអាកាសយានដ្ឋានខេត្តមណ្ឌលគីរី ។

**មាត្រា ៣.-** ត្រូវបានកំណត់ និង បង្កើតទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារចេញ ចូល-ព្រំដែនប្រទេសមានដូចខាងក្រោម :

**១ - ច្រកទ្វារព្រំដែនអន្តរជាតិ :**

**- រាជធានីភ្នំពេញ :**

១- អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង

២- កំពង់ផែពាណិជ្ជកម្មអន្តរជាតិរាជធានីភ្នំពេញ

**- ក្រុងព្រះសីហនុ :**

៣- កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ

**- ខេត្តស្វាយរៀង :**

៤- បាវិត ( លើផ្លូវជាតិលេខ ១ )

**- ខេត្តកណ្តាល-ព្រៃវែង :**

៥- ក្អមសំណរ-កោះរការ ( ទន្លេមេគង្គ )

**- ខេត្តតាកែវ:**

៦- ភ្នំដិន ( លើផ្លូវជាតិលេខ២ )

**- ខេត្តកោះកុង:**

៧- ចាំយាម

**- ខេត្តបន្ទាយមានជ័យ :**

៨- ប៉ោយប៉ែត

**២. ច្រកទ្វារព្រំដែនចេញ-ចូលប្រទេសទ្វេភាគី :**

**- ខេត្តរតនគិរី :**

១- អូរយ៉ាដាវ ( លើផ្លូវជាតិលេខ ១៩ )

**- ខេត្តមណ្ឌលគិរី :**

២- ដាក់ដាំ ( លើផ្លូវជាតិលេខ ១៤ )

**- ខេត្តក្រចេះ :**

៣- ស្នួល ( លើផ្លូវជាតិលេខ ១៣ )

**- ខេត្តកំពង់ចាម :**

៤- ត្រពាំងផ្លុង ( លើផ្លូវជាតិលេខ ៧ )

**- ខេត្តកំពត :**

៥- ព្រែកចាក ( លើផ្លូវជាតិលេខ ១៧ )

**៣. ច្រកទ្វារតំបន់ព្រំដែន :**

**- ខេត្តមណ្ឌលគិរី :**

១- បាឡាខេ ( ផ្លូវគោក )

**- ខេត្តក្រចេះ :**

២- ជ័យឃ្លាំង

៣- វ៉ាលី

**- ខេត្តកំពង់ចាម :**

៤-មេមត់ ( ផ្លូវគោក )

៥- ដា ( ផ្លូវគោក )

៦- ដាំក្រវៀន ( ផ្លូវគោក )

**- ខេត្តព្រៃវែង :**

៧- ពាមមន្ទា ( ផ្លូវទឹក )

៨- កោះសំពៅ ( ផ្លូវទឹក )

**- ខេត្តស្វាយរៀង :**

៩- បុសមន ( ផ្លូវគោក )

១០- ព្រៃវល្លិ ( ផ្លូវគោក )

១១-សំរោង ( ផ្លូវគោក )

- **ខេត្តកណ្តាល :**

១២ - ជ្រៃធំ -ខ្ពាំងយូរ ( ផ្លូវទឹក )

- **ខេត្តតាកែវ :**

១៣ - បាក់ដៃ ( ផ្លូវទឹក )

១៤-កំពង់ក្រសាំង ( ផ្លូវទឹក )

- **ខេត្តកំពត :**

១៥ - ទាន់ហាន់ ( ផ្លូវសមុទ្រ )

១៦- កោះសេះ ( ផ្លូវសមុទ្រ )

១៧- ត្រពាំងល្ពៅ ( ផ្លូវសមុទ្រ )

១៨- ទីរួមខេត្ត ( ផែ )

- **ទីក្រុងកែប :**

១៩- ផែទីក្រុងកែប

- **ក្រុងព្រះសីហនុ :**

២០- ទំនប់រលក ( ផែ )

២១- ស្ទឹងហាវ

- **ខេត្តកោះកុង :**

២២- កោះស្តេច ( ផែ)

២៣- ប៉ាក់ខ្លង ( ផែ)

២៤- ថ្មស

២៥- ស្រែអំបិល

- **ខេត្តពោធិ៍សាត់ :**

២៦- ភ្នំឬស្សី

២៧- ស្ពានជ័យជំនះ ( វាលវែង)

២៨- ប្រកផ្លូវ ៥៦ ( វាលវែង)

- **ខេត្តបន្ទាយមានជ័យ :**

២៩- បឹងត្រកួន

៣០- មេឡៃ

- **ខេត្តឧត្តរមានជ័យ :**

៣១- អូរស្មាច់ ( ផ្លូវគោក )

- **ខេត្តព្រះវិហារ :**

៣២- អានសេះ

- **ខេត្តបាត់ដំបង :**

៣៣- ភ្នំដី

៣៤- សូនស៊ុំ ( កំរៀង )

៣៥- ប៉ៃលិន

៣៦- ច្រក ៤០០ ( សំឡូត )

៣៧- ច្រក ២០៣ ( សំឡូត )

៣៨- ពាមតា ( សំឡូត )

៣៩- បានសានអារ ( សំឡូត )

៤០- ភ្នំព្រឹក ( សំពៅលូន )

៤១- ស្វាយចេក ( កំរៀង )

៤២- អូររំដួល ( កំរៀង )

- **ខេត្តស្ទឹងត្រែង :**

៤៣- អូរស្វាយ-កោះឈើទាលធំ ( ផ្លូវទឹក )

៤៤- ដុងក្រឡ ( ផ្លូវគោក )

**មាត្រា ៤.-** សមាសភាព តួនាទី និងភារកិច្ច របស់កងកម្លាំងប្រដាប់អាវុធ និងភ្នាក់ងារមានសមត្ថកិច្ច ប្រចាំការ នៅតាមទីស្នាក់ការ ត្រួតពិនិត្យមានដូចខាងក្រោម :

**ក.- អំពីសមាសភាព**

**ក១ .- នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ :**

១- មន្ត្រីរដ្ឋបាល មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ប្រធាន

២- កំលាំងនគរបាលជាតិ ផ្នែកអន្តោប្រវេស៍ សមាជិក

៣- ភ្នាក់ងារកាំកុងត្រូល សមាជិក

៤- ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

៥- ភ្នាក់ងារភូត្គគាមអនាម័យ សមាជិក

៦- ភ្នាក់ងារចត្តាឡីសក្តិ សមាជិក

៧- ភ្នាក់ងារត្រួតពិនិត្យឱសថ សមាជិក

**-ដោយឡែកនៅតាម :**

អាកាសយានដ្ឋានអន្តរជាតិ មានអាជ្ញាធរអាកាសចរស៊ីវិល ជាប្រធាន ។

កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ និងទីក្រុងភ្នំពេញមាន ប្រធានមណ្ឌលកំពង់ផែ ជាប្រធាន និងកាំសាបជាសមាជិកថែមទៀត ។

**ក២- នៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន និង ច្រកទ្វារព្រំដែនចេញចូល ប្រទេសទ្វេភាគីកម្ពុជា-ឡាវ.កម្ពុជា-វៀតណាម និងកម្ពុជា-ថៃ :**

១-កំលាំងនគរបាលជាតិ ផ្នែកអន្តោប្រវេសន៍ ជាប្រធាន

២-ភ្នាក់ងារកាំកុងត្រូល សមាជិក

៣-ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

**ក៣- នៅតាមទីស្នាក់ការត្រួតពិនិត្យតាមផ្លូវគោកផ្ទៃក្នុងប្រទេស :**

១- ភ្នាក់ងារគយនិងរដ្ឋាករ

**ក៤- នៅតាមអាកាសយានដ្ឋានផ្ទៃក្នុងប្រទេស :**

១- អាជ្ញាធរអាកាសចរស៊ីវិល ជាប្រធាន

២-កំលាំងនគរបាលជាតិ សមាជិក

៣- ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

**ខ. អំពីតួនាទីភារកិច្ចនៃទីស្នាក់ការត្រួតពិនិត្យ និង កំលាំងត្រួតពិនិត្យនៅតាមទីស្នាក់ការត្រួតពិនិត្យ នីមួយៗ :**

**ខ១. ទីស្នាក់ការត្រួតពិនិត្យនីមួយៗ ត្រូវធានាអោយបានល្អ :**

កិច្ចថែរក្សាការពារអធិបតេយ្យភាព បូរណភាពទឹកដី និង ការអនុវត្តន៍ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា

+ កិច្ចការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

+ គ្រប់គ្រងសេដ្ឋកិច្ច និងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី

+ សំរួលចរាចរដឹកជញ្ជូន ការធ្វើដំណើរទៅមករបស់ប្រជាពលរដ្ឋខ្មែរ និងជនបរទេស

+ រកឱ្យ ឃើញ ទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលា រាល់បទល្មើសច្បាប់នានា ពិសេសបទល្មើសព្រំដែន ។

+ ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួនជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងស្ថាប័នជំនាញសាមី និងចម្លងជូនអភិបាលខេត្តក្រុង ។

**ខ២. តួនាទី ភារកិច្ច និង សិទ្ធិអំណាចរបស់កងកំលាំងនគរបាលជាតិផ្នែកអន្តោប្រវេសន៍ និងភ្នាក់ងារជំនាញមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ត្រូវអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាល និង ប្រកាស សារាចរ របស់ក្រសួងសាមី មានជាអាទិ៍ ដូចខាងក្រោម :**

១-កំលាំងនគបាលជាតិផ្នែកអន្តោប្រវេសន៍ទទួលបន្ទុកគ្រប់គ្រង និងត្រួតពិនិត្យការចេញ - ចូលឆ្លងកាត់ព្រំដែន ត្រួតពិនិត្យការងារចរាចរ ការធ្វើដំណើរទៅមករបស់ជនបរទេស និងជនស៊ីវិលជាប្រជាពលរដ្ឋខ្មែរ បង្ក្រាបបានទាន់ពេលវេលាបទល្មើសឆ្លងដែន និង បទល្មើសផ្សេងៗ រួមជាមួយកំលាំងមានសមត្ថកិច្ចផែកឆេរអាវុធជាតិផ្ទុះ សំដៅរក្សាសន្តិសុខ និងសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ។

-ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋាននគរបាលជាតិ និងជូនប្រធានទីស្នាក់ការ ។

២- ភ្នាក់ងារកាំកុងត្រូលទទួលត្រួតពិនិត្យលើបរិមាណ ទម្ងន់ គុណភាព សភាពផលិតផលនៃទំនិញ នាំចេញ-ចូលព្រមទាំងចេញវិញ្ញាបនប័ត្រលើបរិមាណ ទម្ងន់ គុណភាព និងសភាពផលិតផល នៃទំនិញនាំចេញ-នាំចូល ។

-ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួងពាណិជ្ជកម្ម និងប្រធានទីស្នាក់ការ ។

៣-ភ្នាក់ងារគយនិងរដ្ឋាករសហការជាមួយភ្នាក់ងារជំនាញ នៃក្រសួងស្ថាប័នដែលឈរប្រចាំការ នៅទីស្នាក់ការត្រួតពិនិត្យ ទទួលបន្ទុកក្នុងការត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ទំនិញ ឥវ៉ាន់ អ្នកដំណើរ កញ្ចប់ ឬ ហិបផ្ញើតាមប្រៃសណីយ៍ រូបិយវត្ថុ -លោហធាតុត្បូងថ្មមានតម្លៃ ថ្នាំពុល អាភៀន ដើម្បីធ្វើការប្រមូលពន្ធនាំចេញ-នាំចូល និងពន្ធផ្សេងៗ ព្រមទាំងទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធ និងអំពើវិច្ឆេទកម្មសេដ្ឋកិច្ច ។ល។

-អនុវត្តតាមខ្លឹមសារនៃសារាចរលេខ ០០១ សរ.សហវ.គវ. ចុះថ្ងៃ ទី ០៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងមន្ត្រីគយ និងរដ្ឋាកររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួន ជូនក្រសួង សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងប្រធានទីស្នាក់ការ ។

៤- ភ្នាក់ងារភូតគាមអនាម័យត្រួតពិនិត្យផលិតផល និង ទំនិញមានដើមកំណើតពីរុក្ខជាតិ និងត្រួតពិនិត្យសត្វគ្រប់ប្រភេទ ដែលធ្វើការនាំចេញ និងនាំចូល ។

- អនុវត្តតាមប្រកាសណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

-ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួងកសិកម្ម រុក្ខារ ប្រមាញ់ និងនេសាទ និងប្រធានទីស្នាក់ការ ។

៥-ភ្នាក់ងារត្រួតពិនិត្យឱសថ ទទួលត្រួតពិនិត្យបែបបទនាំចូល-នាំចេញផលិតផលឱសថ វិញ្ញាបនប័ត្រនាំចូល នាំចេញផលិតផលឱសថនិងត្រួតពិនិត្យគុណភាពឱសថ ។

៦- ចត្តាឡីស័ក្តិទទួលបន្ទុកត្រួតពិនិត្យលើវិញ្ញាបនប័ត្រសុខភាពមនុស្ស និង លក្ខណៈអនាម័យ នៃមធ្យោបាយដឹកជញ្ជូនចេញ-ចូល ឆ្លងកាត់ព្រំដែន ។

-ភ្នាក់ងារត្រួត ពិនិត្យឱសថនិងចត្តាឡីស័ក្តិ ត្រូវធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ជូនក្រសួងសុខាភិបាល និងប្រធានទីស្នាក់ការ ។

**មាត្រា ៥.-** ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវរៀបចំសាងសង់ទីស្នាក់ការឱ្យបានរឹងមាំល្អសមស្របតាមសំណង់វប្បធម៌ជាតិ ងាយស្រួលក្នុងការត្រួតពិនិត្យ និងធានាបានការលើក តំកើងមុខមាត់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦.- ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវធ្វើការផ្លាស់ប្តូរក្នុងរយៈពេល ១ ឆ្នាំម្តងហើយ បើសិនបំពេញការងារបានល្អប្រសើរជូនប្រទេសជាតិ គឺអាចពន្យារពេលបំពេញការងារបានម្តងគត់ស្មើនឹង ១ ឆ្នាំទៀត ។

មាត្រា ៧.- ភ្នាក់ងារមានសមត្ថកិច្ចនៅតាមទីស្នាក់ការត្រួតពិនិត្យ ត្រូវមានវត្តមានអនុវត្តភារកិច្ចរបស់ខ្លួន នៅកន្លែងមួយជាកំណត់ (ONE WAY ONE STOP) ដើម្បីសំរួលការងារ បំពេញបែបបទដល់អតិថិជន ដែលនាំទំនិញឆ្លងកាត់ឱ្យបានឆាប់ ។

មាត្រា ៨.- ភ្នាក់ងារមានសមត្ថកិច្ចនៅតាមទីស្នាក់ការត្រួតពិនិត្យ ហើយបែរជាឆ្លៀតប្រើប្រាស់តួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន បង្កអោយមានការលំបាកស្មុគ្រស្មាញ ដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋខ្មែរ ជនបរទេស ភ្ញៀវទេសចរណ៍ ឬ បង្កឱ្យមានការឃឺតយ៉ាវ ដែលគ្មានមូលហេតុដល់ការនាំចេញ-នាំចូល ការដឹកជញ្ជូនទំនិញ សំភារៈ វត្ថុធាតុដើម និងផលិតផលផ្សេងៗ របស់ក្រុមហ៊ុន ឬ ឯកជន និងធ្វើឱ្យមានការរាំងស្ទះក្នុងការប្រមូលពន្ធ ត្រូវផ្តន្ទាទោសតាម ច្បាប់ជាធរមាន ។

មាត្រា ៩.- ភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ និងយ៉ាងសកម្មប្រកបដោយអាកប្បកិរិយាសុភាពរាបសារ ជៀសវាងបាននូវ ការប៉ះទង្គិចខាងសតិអារម្មណ៍ ចំពោះប្រជាពលរដ្ឋ អ្នកធ្វើដំណើរទូទៅ ដោយគ្មានមូលហេតុសមស្រប ។

មាត្រា ១០.- ភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ លើកលែងតែភ្នាក់ងារគយ និងរដ្ឋាករ ក្រសួងស្ថាប័នសាមីត្រូវធ្វើការផ្លាស់ប្តូរក្នុងរយៈពេល០៦ខែម្តង និងត្រូវធ្វើបញ្ជីរាយនាមភ្នាក់ងារមានសមត្ថកិច្ចទាំងនោះមក ទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់លើកផ្លាស់ប្តូរម្តងៗ ។ បើភ្នាក់ងារណាបំពេញការងារបានល្អប្រសើរជូនប្រទេសជាតិ គឺត្រូវអាចពន្យាពេលបានម្តងគត់ស្មើនឹង ០៦ ខែទៀត ។

មាត្រា ១១.- ក្រុម ឬ ជនប្រដាប់អាវុធ ដែលបង្កើតទីស្នាក់ការត្រួតពិនិត្យអនាធិបតេយ្យ បង្កឱ្យមានការឃឺតយ៉ាវដល់ការធ្វើដំណើរការដឹកជញ្ជូនទំនិញ សំភារៈ វត្ថុធាតុដើម ឬ បាត់បង់ទ្រព្យសម្បត្តិអាយុជីវិតរបស់ប្រជាពលរដ្ឋខ្មែរ និងជនបរទេស ត្រូវធ្វើការដកហូតមុខងារ ឬ ពិន័យផ្នែករដ្ឋបាល ឬ បញ្ជូនខ្លួនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ១២.-** អភិបាលខេត្ត-ក្រុងសាមីតំណាងឱ្យរាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងរបស់ទីស្នាក់ការត្រួតពិនិត្យ និងសំរបសំរួលដល់ការងារដើម្បីធ្វើឱ្យទីស្នាក់ការ ត្រួតពិនិត្យមានដំណើរការរលូនសមស្របតាមសំណូមពរអតិថិជន និងធានាក្នុងការអនុវត្តន៍ច្បាប់នានា។ ក្រៅពីនេះ ត្រូវទទួលខុសត្រូវក្នុងការបង្ក្រាបនិងលុបបំបាត់កំលាំងដែលបង្កើតទីស្នាក់ការត្រួតពិនិត្យអនាធិបតេយ្យក្នុងដែនដីដែលខ្លួនគ្រប់គ្រង ។

-ក្នុងករណីកំលាំងអនាធិតេយ្យនៅតែបង្កើតទីស្នាក់ការត្រួតពិនិត្យចល័ត ផ្ទុយពីខ្លឹមសារអនុក្រឹត្យនេះ រាជរដ្ឋាភិបាលនឹងដកហូតមុខងាររបស់អភិបាលស្រុក-ខ័ណ្ឌសាមី ឬក្នុងករណីធ្ងន់ធ្ងរ អាចដកហូតមុខងាររបស់អភិបាលខេត្ត-ក្រុងសាមី តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

-ដោយឡែក នៅកំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ អាជ្ញាធរក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកដោះស្រាយរាល់បញ្ហានិងបាតុភាពផ្សេងៗ ដែលកើតមានឡើងដើម្បីសម្របសម្រួលការងារ ឱ្យមានភាពជឿនលឿន និងឆាប់រហ័ស ។

**មាត្រា ១៣.-** ក្រុមគយ និងរដ្ឋាករចល័ត ដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់នាយកទីចាត់ការគយ និងរដ្ឋាករ មានភារកិច្ចធ្វើការស្រាវជ្រាវ និងបង្ក្រាបអំពើរត់គេចពន្ធពីច្រកទ្វារព្រំដែនចូលមកផ្ទៃក្នុងប្រទេស ។

-ក្រុមគយនិងរដ្ឋាករចល័តនេះ អាចចេញធ្វើប្រតិបត្តិការឃាត់តាម មធ្យោបាយដឹកទំនិញបានក្នុងពេលណាដែលទទួលពិតមានថា មធ្យោបាយដឹកទំនិញនោះ កំពុងប្រព្រឹត្តអំពើរត់គេចពន្ធពីព្រំដែនចូលមកផ្ទៃក្នុងប្រទេស និងមានបញ្ជាបេសកកម្មពី នាយកទីចាត់ការគយនិងរដ្ឋាករ តាមករណីជាក់ស្តែងនីមួយៗ មិនអនុញ្ញាតឱ្យក្រុមគយ និង រដ្ឋាករចល័តនេះធ្វើសកម្មភាពបែបអនាធិតេយ្យឡើយ ។

**មាត្រា ១៤.-** ក្រសួង ស្ថាប័នសាមីដែលមានកម្លាំងនៅតាមទីស្នាក់ការត្រួតពិនិត្យដែលចែងក្នុងអនុក្រឹត្យនេះ ត្រូវសហការជាមួយអភិបាលខេត្ត-ក្រុង ដើម្បីធ្វើអធិការកិច្ចជាប់ជាប្រចាំនៅលើទីស្នាក់ការត្រួតពិនិត្យ និងត្រូវរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនមកទីស្តីការគណៈរដ្ឋមន្ត្រីរៀង រាល់ខែ ។

**មាត្រា ១៥.-** អនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៦.-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំ រាជធានីភ្នំពេញ ប្រចាំក្រុងកែប ប្រចាំក្រុងប៉ៃលិន និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃ ទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

***

## ២.សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧

### សេចក្តីសំរេច លេខ ២៩ សសរ

### ស្តីពី

### ការផ្តត់ផ្គង់ប្រេងឥន្ធនៈជូនគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ក្រុមហ៊ុនវិនិយោគនានា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១០៩៤ /៩៣ ចុះថ្ងៃ ទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា